ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ១៩ ត.ព
ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២
**សាលដីកា**
លេខ ៤៥៦ "ជ"
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍បាត់ដំបង**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាម ព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

17-10-22
សស 12?

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ ១៩ ត.ព ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ មានជនជាប់ចោទដូចខាងក្រោម ៖

១.ឈ្មោះ [redacted] សុខឡា ហៅ ភួ ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិទឹកថ្លា សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងមានទីលំនៅបច្ចុប្បន្ននៅភូមិអារញ្ញ សង្កាត់



Scanned with CamScanner

សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ៥ឆ្នាំ ។ (ក្នុងឃុំ) (មិនប្ដឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៣០ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ។

-ដោយមានលោក [redacted] ម៉ៅ អគ្គលេខ ១៧២៧ ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទ ។

២.ឈ្មោះ[redacted] លីកផៃ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ [redacted] គង (រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៤នាក់ ទោសពីមុន “គ្មាន” ។ (ក្នុងឃុំ) (មិនប្ដឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤២៩ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ ។

-ដោយមានលោក[redacted] សុភា អគ្គលេខ ២៩៤ និងលោ[redacted] ម៉េង អគ្គលេខ ៥០៤ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

៣.ឈ្មោះ[redacted] មួយនី ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្ដីឈ្មោះ[redacted] មានកូនចំនួន ០៤នាក់ ទោសពីមុន “គ្មាន” ។ (គេចខ្លួន)

-ដោយមានលោក[redacted] សុភា អគ្គលេខ ២៩៤ និងលោក[redacted] ម៉េង អគ្គលេខ ៥០៤ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៦ មានករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ខេត្តសៀមរាប បង្កឡើងដោយឈ្មោះ[redacted] លីកផៃ និង ឈ្មោះ [redacted] សុខឡា ហៅ ក្លូ ដោយហេតុថាឈ្មោះ[redacted] សុខឡា បានទទួលលុយពីភ្នាក់ងារ K7 ចំនួន ៣.៣០០.០០០ (បីលានបីសែន) រៀល រួចហើយក៏ចេញទៅបន្ទាប់មកក៏មានគេទំនាក់ទំនងមកភ្នាក់ងារសម្ងាត់ K7 ដោយទំនាក់ទំនងតាមលេខទូរស័ព្ទ ០៦៩ ៨៥ ៤០ ៤២ ជាសម្លេងមនុស្សស្រីបាននិយាយថា បន្តិចទៀតមានគេយកឥវ៉ាន់ (ថ្នាំញៀន) ទៅឱ្យហើយ ។ ភ្លាមនោះក៏ឃើញមានជនសង្ស័យម្នាក់ឈ្មោះ [redacted] លីកផៃ ដឹកកូនចំនួន ០៣នាក់ មកឈប់នៅកន្លែងណាត់ជួបនៅចំណុចជិតរង្វង់មូលផ្លូវ៦០ម៉ែត្រ បានប្រគល់របស់មួយដុំក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្ដង ។ បន្ទាប់មកសមត្ថកិច្ចក៏បានទៅឆែកឆេរនៅផ្ទះរបស់ជនសង្ស័យឈ្មោះ[redacted] លីកផៃ រឹបអូសបានម្សៅសថ្លាចំនួន ១៥កញ្ចប់ មានទម្ងន់សរុប



Scanned with CamScanner

១៨៥៤,៤០ក្រាម, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០២គ្រឿង, ថង់តែអាលុយមីញ៉ូមសម្រាប់វេចខ្ចប់គ្រឿងញៀនចំនួនមួយ ។ ហើយឈ្មោះ [redacted] សុខឡា ជាអ្នកទទួលប្រាក់ និងវេរលុយទៅឱ្យឈ្មោះ [redacted] ហៅ ស្រីពៅ រហ័សនាម "កន្សែងក្រហម" ភេទស្រី ។ បច្ចុប្បន្នឈ្មោះ [redacted] ហៅ ស្រីពៅ កំពុងជាប់ឃុំនៅក្នុងពន្ធនាគារខេត្តសៀមរាប កាន់ទូរស័ព្ទលេខ ០៦៩ ៨៥ ៤០ ៤២ និងឈ្មោះ [redacted] លីកថៃ ជាអ្នកយកថ្នាំញៀនប្រគល់ទៅឱ្យភ្នាក់ងារ K7 ។ ចំណែកឈ្មោះ [redacted] មួយនី ភេទស្រី អាយុ៣៥ឆ្នាំ ត្រូវជាប្រពន្ធឈ្មោះ [redacted] លីកថៃ ជាអ្នកវេរប្រាក់ថ្លៃទិញលក់គ្រឿងញៀនបានរត់គេចខ្លួនបាត់ទៅខណៈពេលដែលសុំទៅមើលកូនឈឺនៅឯមន្ទីរពេទ្យ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៩៤ "ឃ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ផ្ដន្ទាទោសឈ្មោះ [redacted] លីកថៃ ភេទប្រុស ជនជាតិខ្មែរ អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ឆ្នាំ (សាមសិប)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១00.000.000 (មួយរយលាន)រៀល ។

២.ផ្ដន្ទាទោសឈ្មោះ [redacted] សុខឡា ហៅ អាក្ដូ ភេទប្រុស ជនជាតិខ្មែរ អាយុ២៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ២៥ (ម្ភៃប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦0.000.000 (ហុកសិបលាន) រៀល ។

៣.ផ្ដន្ទាទោសឈ្មោះ [redacted] មួយនី ភេទស្រី ជនជាតិខ្មែរ អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ២៥ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦0.000.000 (ហុកសិបលាន)រៀល ។

ពីបទ "ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] មួយនី យកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ស្របតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥.វត្ថុតាងដែលចៅក្រមស៊ើបសួរបានរក្សាទុកក្នុងដីកាបង្គាប់ឱ្យរក្សាទុកវត្ថុដែលចាប់យកលេខ៖ ២៣១/២០២០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ មាន៖ ១/.ស្រោមសំបុត្របិទជិត ពណ៌ត្នោតខ្ចីចំនួន ០២កញ្ចប់ធំ (មានស្នាមមេដៃផ្ដិតមេដៃរបស់ឈ្មោះ [redacted] លីកថៃ និងហត្ថលេខាសមាសភាពចូលរួម) ។ ២/.ទឹកចម្រាញ់ថ្នាំញៀនចំនួន ០១ដប ។ ៣/.ជញ្ជីងចំនួន ០២គ្រឿង មានពណ៌សមួយគ្រឿង និងពណ៌ខ្មៅមួយគ្រឿង ។ ៤/.ទូរស័ព្ទដៃចំនួន ០៤គ្រឿង ម៉ាក NOKIA ចុចពិល ពណ៌ខ្មៅ ចំនួន ០២គ្រឿង, ម៉ាក Iphone6 ពណ៌ខ្មៅ ចំនួន ០១គ្រឿង និងម៉ាក OPPO ពណ៌ក្រហម ចំនួន ០១គ្រឿង ។ ៥/.ឆ្នាំងម៉ាក KHALUCK ពណ៌ក្រហម ចំនួន ០១គ្រឿង ។ ៦/.ធុងពណ៌ខៀវ ចំនួន០១គ្រឿង ។ ៧/.



Scanned with CamScanner

ឧបករណ៍ប្រើប្រាស់ និងឧបករណ៍សម្រាប់ច្រកថ្នាំញៀនមួយចំនួន ។ វត្ថុតាងទាំងអស់នេះសម្រេចរឹបអូស ស្របតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

៦.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីកផៃ និងឈ្មោះ [redacted] សុខឡា និងកំបាំងមុខជនជាប់ចោទ [redacted] មួយនី ។

បើកសិទ្ធិអោយប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣២៩ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់លោក [redacted] ពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សុខឡា ហៅ ក្លូ ក្នុងការប្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៤ "ង" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចនៃសេចក្តីសម្រេច ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៣៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់លោក [redacted] សុភ័ក្រ្ត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីកផៃ ក្នុងការប្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៤"ង" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៤៨ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] លីកផៃ ក្នុងការប្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៤"ង" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩៩ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ របស់លោក [redacted] សុភា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី ក្នុងការប្តឹងឧទ្ធរណ៍ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៤ "ង" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៦ (ង) ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលបានសម្រេច៖

១/.ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣២៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ របស់លោក [redacted] ពិសិដ្ឋ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខឡា ហៅ ក្លូ, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៣៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់លោក [redacted] សុភ័ក្រ្ត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីកផៃ ហៅ ផៃ, ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៤៨ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] លីកផៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានតាមផ្លូវច្បាប់ ។

២/.ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៣៩៩ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ របស់លោក [redacted] សុភា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

៣/.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩៤ "ជ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល លើកលែង ចំណុចស្តីពីការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លីកឆៃ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ (សាមសិប)ឆ្នាំ និងចំណុចស្តីពីការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] មួយនី ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ២៥ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល ត្រូវកែប្រែមកជា៖

៣.១ ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លីកឆៃ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ២៥(ម្ភៃប្រាំ)ឆ្នាំ ។

៣.២ ឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី ដែលមានសាវតាជាតិដូចខាងលើបានរួចផុតពីបទចោទបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.បង្គាប់ឱ្យបញ្ឈប់ចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] មួយនី ដែលមានសាវតាជាតិដូចខាងលើ ។

ចំណុចផ្សេងពីនេះត្រូវរក្សាទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះនាសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីកឆៃ និងជនជាប់ចោទឈ្មោះ [redacted] សុខឡា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] មួយនី និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ០៧ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញាមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ង" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រង់ចំណុច៖

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លីកឆៃ ដាក់ពន្ធនាគាររយៈពេល ២៥ឆ្នាំ និងគ្មានការពិន័យជាប្រាក់ទៅតាមបញ្ញត្តិមាត្រាដែលបានចែង និងចោទប្រកាន់ ។

២.ឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី រួចផុតពីបទចោទបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០



Scanned with CamScanner

បទល្មើសព្រហ្មទណ្ឌមានបញ្ញត្តិ និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ និងទី៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ ពាក្យបណ្តឹងសាទុក្ខលេខ ១៦ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់លោ[redacted]វីរៈ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សុខឡា ហៅ ក្លូ ក្នុងការប្តឹងសាទុក្ខ បានប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ង" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាលេខ ២៧៦ "III" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់តុលាការកំពូលដែលបានសម្រេច៖

១.ទទួលបណ្តឹងសាទុក្ខលេខ ០៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង និងបណ្តឹងសាទុក្ខលេខ ១៦ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់លោក[redacted] វីរៈ មេធាវីទទួលសិទ្ធិតំណាងឱ្យជនជាប់ចោទឈ្មោ[redacted]សុខឡា ហៅ ក្លូ ក្នុងការប្តឹងសាទុក្ខ ។

២.បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៣៦ "ង" ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រង់ចំណុចទី៣, ៣.១, ៣.២ និងចំណុចទី៤ នៃសេចក្តីសម្រេច ។

៣.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍បាត់ដំបងជំនុំជម្រះសាជាថ្មីឡើងវិញត្រង់ចំណុចដែលបានបដិសេធ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ។

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ៣០៥ ព្រទ.ឧបប/២២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោះ[redacted]សុខឡា បានឆ្លើយថា៖ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល ខ្លួនបានខលទៅមិត្តភក្តិខ្លួនឈ្មោះ ស្មី ហើយខលទៅរឿងខ្ចីលុយព្រោះគេធ្លាប់ខ្ចីខ្លួនហើយខ្លួនធ្លាប់ខ្ចីគេ ។ នៅថ្ងៃនឹងមិត្តភក្តិខ្លួនឈ្មោះ ស្មី នឹងឱ្យខ្លួនជិះមកយកនៅមុខសាលារៀន



Scanned with CamScanner

ទាល់តែពេលខ្លួនជិះទៅវាឱ្យខ្លួន១០ម៉ឺន ហើយលុយ ១០ម៉ឺនរៀល នោះខ្លួនបានហើយខ្លួនយកទៅហូបអីអស់៤ម៉ឺន នៅសល់៦ម៉ឺន ។ បន្ទាប់មកនៅម៉ោង ២ រសៀលជាងនឹងខ្លួនទៅផ្លាស់ខោអាវដល់ម៉ោងទៅហាត់ប្រាណដល់ម៉ោង ៤ ជាង ខ្លួនត្រឡប់មកវិញដល់បន្ទប់ជួលម្នាក់ស្រីដែលខ្លួនស្គាល់នឹង ដល់បន្ទប់ជួលនឹងខ្លួនស្លៀកពាក់ខោអាវរៀបនឹងចេញទៅញ៉ាំអីមានថៃម្នាក់គាត់តេមកខ្លួនហើយសួរខ្លួនថា នៅសៀមរាបនឹងមានដឹងថាអ្នកណាកើតអ្វីអត់ ខ្លួនថារឿងកើតអ្វីខ្លួនមិនដឹងទេ ខ្លួនរវល់ពាក់ខោអាវសិន ចាំពាក់ខោអាវរួចចាំខលទៅវិញ ទាល់តែខ្លួនពាក់ខោអាវហើយខ្លួនក៏ខលទៅគាត់ថាថៃឯងចង់សួររឿងគាត់ក៏ឆ្លើយថា សួរសុខទុក្ខធម្មតា ។ ខ្លួនជិះចេញពីបន្ទប់ជួលនៅចំណុចក្រោយផ្សារលើសមត្ថកិច្ចឃាត់ខ្លួន ហើយដកហូតខ្លួនមានលុយតែ៦ម៉ឺននឹងទេ ។ ចំពោះថ្នាំញៀន ១០០ក្រាម នឹងមិនមែនជារបស់ខ្លួនទេ ហើយខ្លួនមិនបានដឹងអ្វីនោះទេ ព្រោះនៅថ្ងៃកើតហេតុខ្លួនបានទៅយកលុយពីមិត្តភក្តិខ្លួនឈ្មោះ ស្មី នឹងតែ១០ម៉ឺនរៀល នឹងទេ ។ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។

-ជនជាប់ចោទឈ្មោះ [redacted] លីកផៃ បានឆ្លើយថា៖ នៅពេលដែលសមត្ថកិច្ចចាប់ខ្លួនខ្លួនដឹកកូនខ្លួនមកផ្ទះ ពេលនឹងប្រពន្ធខ្លួនក៏នៅផ្ទះដែរ ហើយសមត្ថកិច្ចពីរនាក់នឹងក៏ឆែកប្រពន្ធខ្លួនដែរ ហើយប្រពន្ធខ្លួនក៏ថាឆែកទៅ ពីព្រោះប្រពន្ធខ្លួនមិនបានដឹងរឿងអ្វីនោះទេ ហើយគ្រឿងញៀនខ្លួនបានលាក់ទុកនៅបន្ទប់ជាន់លើក្នុងធុងវេចថង់ខ្មៅមានកាសែតរុំពីក្រៅដែលជាបន្ទប់ទំនេរ ។ នៅពេលដែលឆែកឃើញរបស់ហើយ សមត្ថកិច្ចជូនខ្លួនមកផ្ទះថាថៃនឹងមិនពាក់ព័ន្ធទេ បើថៃនឹងពាក់ព័ន្ធគាត់យកគ្រឿងញៀននឹងទៅបោះចោលហើយ ហើយប្រពន្ធខ្លួនបានយកបាយទឹកមកឱ្យខ្លួននៅកន្លែងប៉េអឹមគឺចំនួន៣ថ្ងៃ ទាំងព្រឹកទាំងល្ងាច ទាល់តែដល់ថ្ងៃគេបញ្ជូនខ្លួនមកតុលាការក៏មានឈ្មោះប្រពន្ធខ្លួនដែរ ។ នៅពេលដែលសមត្ថកិច្ចឆែកឆេរឃើញគ្រឿងញៀននឹងគាត់ក៏នៅផ្ទះនឹងដែរ ហើយគាត់មិនដឹងថាមានគ្រឿងញៀននៅផ្ទះនោះទេ ហើយខ្លួនក៏មិនដែលបានជួញដូរថ្នាំញៀនដែរ គឺខ្លួនស៊ីឈ្នួលគេហើយគេប្រាប់ខ្លួនថាជារបស់ប៉ូវកំលាំងហើយឱ្យខ្លួនយកទៅឱ្យគេ ។ ប្រពន្ធរបស់ខ្លួនឈ្មោ[redacted]មួយនី គាត់មិនបានដឹងថា ខ្លួនពាក់ព័ន្ធនឹងរឿងគ្រឿងញៀននឹងទេ ពីមុនក៏ខ្លួនមិនដែលរកស៊ីគ្រឿងញៀននឹងដែរ ខ្លួនឱបភៀវ ។ ខ្លួន និងប្រពន្ធរបស់ខ្លួនរស់នៅជាមួយគ្នាប្រហែល ៨ឆ្នាំ នៅសម័យកូវីដនឹងមានគេមកប្រាប់ខ្លួនថាចាំយកតែរបស់ឱ្យគេតាមបញ្ជាលេខទូរស័ព្ទ ចំពោះរបស់នឹងគឺខ្លួនមិនថាជាគ្រឿងញៀននោះទេគេប្រាប់ខ្លួនថា ជាថ្នាំប៉ូវកំលាំង យកទៅឱ្យគេមួយដងឱ្យថ្លៃដឹក ២៥ ដុល្លារ ។ នៅពេលដែលខ្លួនទៅយកថ្នាំញៀននឹងគឺខ្លួនជិះម៉ូតូទៅជាមួយកូនចំនួន ៣នាក់ ។ ខ្លួនមិនបានដឹងថារបស់ដែលខ្លួនដឹកនឹងជាគ្រឿងញៀនផង បើសិនជាខ្លួនដឹងថារបស់នឹងជាគ្រឿងញៀន ខ្លួនមិនដឹកឱ្យគេនោះទេ ។ នៅពេលដែលសមត្ថកិច្ចចាប់ខ្លួនគឺខ្លួនមិនបានតបតជាមួយសមត្ថកិច្ចទេ ។ ខ្លួនមានកូនទាំងអស់ចំនួន ៤នាក់ ខ្លួនរៀនត្រឹមថ្នាក់ទី១១ ។ ខ្លួនយកថ្នាំញៀននឹងទៅទុកនៅផ្ទះប្រហែលបីថ្ងៃហើយ ។ សមត្ថកិច្ចឃាត់ខ្លួន ១ម៉ោងរួចហើយទើបទៅឆែកនៅផ្ទះខ្លួន ។ សំណូមពរ ក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចតម្កល់សាលដីការបស់សាលា



Scanned with CamScanner

ឧទ្ធរណ៍ទុកជាបានការដដែរ ។ ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted]សុខឡា នោះទេ ។ ខ្លួនទើបតែយករបស់ឱ្យគេនឹងជាលើកទី១ទេ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនតែម្តង ។

-សាក្សីឈ្មោះ[redacted]ច័ន្ទតារា បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ចំពោះលិខិតបញ្ជាក់មួយជាលិខិតបំភ្លឺចំពោះអង្គជំនុំជម្រះធ្វើនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ដែលមានខ្លឹមសារដោយខ្លួនបានបញ្ជាក់ថា ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ ក្លូ នេះ គាត់មិនបានពាក់ព័ន្ធនឹងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះទេ គាត់ពាក់ព័ន្ធតែលុយចំនួន ១០.០០០០ (ដប់ម៉ឺន)រៀលតែប៉ុណ្ណោះ បញ្ជាក់នៅក្នុងពន្ធនាគារ ។ នៅពេលដែលបង្ក្រាបនឹងគឺយើងពិនិត្យទៅលើបុគ្គលដែលគ្មានអត្តសញ្ញាណបុគ្គលដែលមិនស្គាល់ឈ្មោះដែលបណ្តាញយើង K7 រាយការណ៍មកឱ្យតែលេខទូរស័ព្ទ ប៉ុន្តែដោយយើងដាក់ឈ្មោះ[redacted]សុខឡា នឹងដោយសារកម្លាំងយើងជួបគាត់មុនគេ ជួបហើយឃើញហុចលុយហើយដែលមានលោក[redacted]ណាក់ មកដែរ គាត់ជាអ្នកតាម ជួបឃើញហុចលុយយើងក៏ដើរទៅជួបគាត់ហើយក៏រាយការណ៍ទៅមេថាយកពីណាក៏ឃើញលុយដែលយើងសរសេរកត់ទុកនៅក្នុងសំណុំរឿង ឃើញលុយរបស់ខ្លួននឹងគឺមាននៅឈ្មោះ [redacted] សុខឡា ៣ ទៅ៤សន្លឹក ខ្លួនមិនចាំដែរព្រោះពីរឆ្នាំហើយ ដឹងតែថាមានលុយរបស់យើងនៅនឹងឈ្មោះ[redacted] សុខឡា ។ ថ្នាំញៀន ១ខាំ នឹងមិនមែនជារបស់ឈ្មោះ [redacted] សុខឡា ទេ គឺយើងទៅយកពីឈ្មោះ[redacted] លីកផៃ មក ។ ចំពោះលុយគឺខ្លួនប្រគល់ឱ្យទៅ K7 ដោយមានថតទុកស្រេចមានភស្តុតាងជាឯកសារក្នុងសំណុំរឿង ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតបានចំនួន ១ខាំ នឹងគឺមិនមែនដកហូតបានពីឈ្មោះ[redacted] សុខឡា នោះទេ គឺដកហូតបានមកពីឈ្មោះ [redacted]លីកផៃ ។ នៅពេលចុះបង្ក្រាបនៅផ្ទះឈ្មោះ[redacted] លីកផៃ គឺខ្លួនបានជួបប្រពន្ធគាត់នៅនឹងដែរ ប៉ុន្តែមិនបានឃាត់ប្រពន្ធរបស់គាត់ទេ ប៉ុន្តែក្រោយមកប្រពន្ធគាត់ក៏បានយកបាយទឹកទៅឱ្យឈ្មោះ [redacted] លីកផៃ ចំនួន ៣ថ្ងៃ គាត់យកទៅទាំងព្រឹកទាំងថ្ងៃ ហើយប្រពន្ធគាត់មិនមានសកម្មភាពជួញដូរគ្រឿងញៀនឡើយ ហើយភស្តុតាងដាក់បន្ទុកលើឈ្មោះ[redacted] មួយនឹ មិនមានឡើយ គ្រាន់តែឃើញវេរលុយចេញចូលតែប៉ុណ្ណោះ ។

-សាក្សីឈ្មោះ[redacted]ណាក់ បានឆ្លើយថា៖ នៅពេលឃាត់ខ្លួនឈ្មោះ [redacted]សុខឡា ហៅក្លូ នឹងបានឆែកឆេរទៅលើឈ្មោះ [redacted] សុខឡា ឃើញតែក្រដាសប្រាក់ មិនបានឃើញថ្នាំញៀននៅនឹងខ្លួនរបស់ឈ្មោះ[redacted] សុខឡា នោះទេ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាពិនិត្យ និងសម្រេចតាមច្បាប់ ។

-លោក[redacted]ម៉ា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សុខឡា បានធ្វើសេចក្តីសន្និដ្ឋានថា៖ សំណុំរឿងនេះត្រូវបានតុលាការកំពូលបង្វិលមកឱ្យសាលាឧទ្ធរណ៍បាត់ដំបងធ្វើការជំនុំជម្រះឡើងវិញ ដោយតុលាការកំពូលបដិសេធសាលដីកាលេខ ៣៦ (ង) ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ដែលសាលដីការបស់សាលាឧទ្ធរណ៍បាត់ដំបង បាន



Scanned with CamScanner

សម្រេចតម្កល់សាលក្រមលេខ ១៦៤ "ជ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប សាលក្រមរបស់សាលាដំបូងខេត្តសៀមរាបនេះបានសម្រេច និងប្រកាសពិរុទ្ធភាពដាក់ទោសទៅលើឈ្មោះ [redacted] សុខឡា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដាក់ទោសចំនួន ២៥ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យចំនួន ៦០.០០០.០០០ (ហុកសិបលាន) បានន័យថា តុលាការកំពូលបដិសេធបានន័យថាទៅឱ្យសាលាឧទ្ធរណ៍ពិចារណាឡើងវិញចំពោះទោស និងពិន័យទៅលើជនជាប់ចោទនឹងពិរុទ្ធភាពទៅលើជនជាប់ចោទឈ្មោះ [redacted] សុខឡា នេះ ។ ផ្អែកតាមសាលដីកានេះកត់សម្គាល់ឃើញមានពីរចំណុចដែលតុលាការកំពូលបានចង្អុលបង្ហាញទី១ គប្បីសាលាឧទ្ធរណ៍ធ្វើការពិចារណាផ្ទៀងផ្ទាត់ទៅលើភស្តុតាងអង្គហេតុផ្សេងទៀតដើម្បីស្វែងរកអង្គហេតុពិតរកយុត្តិធម៌ឱ្យជនជាប់ចោទឈ្មោះ [redacted] សុខឡា ហៅ ក្លូ ។ ចំណុចទី២ តុលាការកំពូលបានចង្អុលបង្ហាញថាតុលាការថ្នាក់ក្រោមពុំទាន់បានញែកបរិមាណចំនួនសារធាតុញៀនដែលដកចេញពីជនជាប់ចោទនៅក្នុងអង្គហេតុដាច់ដោយឡែកពីគ្នា ក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនរបស់ជនជាប់ចោទម្នាក់ៗ ដើម្បីកំណត់កម្រិតទណ្ឌកម្មផ្អែកទៅលើសារធាតុញៀនសកម្មភាពជួញដូរដាច់ដោយឡែកពីគ្នា ។ ចំណុចពីរនេះហើយដែលខ្លួនទទួចសុំឱ្យសាក្សីឈ្មោះ [redacted] ច័ន្ទតារា ដែលកាលនោះលោកជាមន្ត្រីនគរបាលយុត្តិធម៌ និងជានាយការិយាល័យក្នុងការបង្ក្រាប និងធ្វើសកម្មភាពនេះដោយលោកបានកសាងនឹងរៀបចំឯកសារផ្ទាល់ដោយលោកបញ្ជូនមកតំណាងអយ្យការដែលតំណាងអយ្យការធ្វើការចោទប្រកាន់នៃទោស ។ ពាក់ព័ន្ធចំណុចទី១ ផ្ទៀងផ្ទាត់ទៅនឹងអង្គហេតុពិតតុលាការឱ្យរកអង្គហេតុពិតឥឡូវនេះអង្គហេតុពិតបានបញ្ជាក់ឃើញហើយថា ឈ្មោះ [redacted] សុខឡា នេះគាត់បានពាក់ព័ន្ធតែលុយចំនួន ១០ម៉ឺនរៀល ដែល១០ម៉ឺនរៀលនេះ K7 ដែលជាកម្លាំងបង្កប់នេះគាត់បានបញ្ជាក់ថា លោក [redacted] ច័ន្ទតារា គាត់ប្រគល់លុយឱ្យ ៣.៣០០.០០០ (បីលានពីរសែន) រៀល ទៅទិញគ្រឿងញៀន ប៉ុន្តែគាត់មិនបានដឹង K7 នឹងឈ្មោះ រស្មី គាត់មិនបានដឹងថាលុយនោះខាងកម្លាំងនគរបាលយុត្តិធម៌ខាងលោក [redacted] ច័ន្ទតារា នេះថតទុកទេ គាត់ទាក់ទងទៅទិញគ្រឿងញៀនពីឈ្មោះ [redacted] ហៅ ស្រីពៅ នឹងដែលមានកន្ទុយលេខ ៤២ នឹងគាត់ដកលុយ ១០.០០០០ (ដប់ម៉ឺន)រៀល នឹងទុកគាត់ថាគាត់មានលុយណា ៣.២០០.០០០ (បីលានពីរសែន) រៀលនោះទេ តាមពិតលុយដែល [redacted] ច័ន្ទតារា ឱ្យទៅនឹង ៣.៣០០.០០០ (បីលានបីសែន)រៀល អញ្ចឹងរស្មីគិតថាទិញតែ ៣.២០០.០០០ (បីលានពីរសែន) រៀល ទុក ១០.០០០០(ដប់ម៉ឺន)រៀល ចាយ ។ ក្រោយមកពេល K7 វេរលុយទៅឱ្យឈ្មោះ យ៉ា តាមកន្ទុយលេខ ៤២ នឹង ចន្លោះពេលនឹងឈ្នួលបង្កើតជាមិត្តភក្តិរបស់ឈ្មោះ រស្មី គាត់ក៏គេខ្ចីលុយជួបក៏ឱ្យថែមលុយ ដូច្នេះហើយបានលោក [redacted] ច័ន្ទតារា ក៏ដូចលោកមេក្តាគាត់បានបញ្ជាក់ថា នៅពេលដែលគាត់ប្រណាំងតាមគាត់ឃើញហុចលុយក្រោយពីចាប់ជននេះបានហើយត្រូវបានឃាត់ខ្លួន [redacted] សុខឡា ទៅ ហើយព័ត៌មាននេះក៏មិនទទួលបានពាក់ព័ន្ធនឹងកូវីដផងហើយគាត់ផ្លាប់ទៅប្រចាំហាងនៅនេះផងធ្វើឱ្យគាត់មិនទទួលបានព័ត៌មានច្បាស់ពី K7 ថា



Scanned with CamScanner

តើលុយនឹងគឺជាលុយអ្វីហើយបានជារបាយការណ៍សន្និដ្ឋានថា មានការជាប់ពាក់ព័ន្ធលក់១ខាំ ហើយលោកបានបញ្ជាក់ហើយថា ដូច្នេះគ្រឿងញៀននឹងគឺមិនមានពាក់ព័ន្ធបទល្មើសគ្រឿងញៀន ដែលមានឈ្មោះ [redacted] លីកវៃ នឹងគឺមិនមានពាក់ព័ន្ធនឹងឈ្មោះ ភ្លូ ទេ ដូចគ្រឿងញៀន១ខាំ ដែរ ។ នេះគឺជាអង្គហេតុពិតដូចដែលថា ការជួញដូរដែលមានការផ្តន្ទាទោសរហូតដល់ ២៥ឆ្នាំ ធ្លាក់ទៅលើឈ្មោះ [redacted] សុខឡា នឹងគឺអយុត្តិធម៌ជាខ្លាំង ។ ចំណុចទី២ តុលាការកំពូលថាឱ្យវែកញែកគ្រឿងញៀនដែលដកបានពីជនជាប់ចោទតាមអង្គហេតុនៃរឿងនេះក៏ដូចជាធាតុសត្យានុម័តគឺគ្រឿងញៀនពេលចាប់បានជាក់ស្តែងគឺឈ្មោះ [redacted] លីកវៃ ជាអ្នកប្រគល់ទោះបីជាលោកដឹងមិនដឹងតែគេចាប់បាននៅលើឈ្មោះ [redacted] លីកវៃ ពេលទៅឆែកនៅផ្ទះឈ្មោ[redacted] លីកវៃ ទាំងសម្ភារៈ និងវត្ថុញៀននឹងគឺគ្រឿងញៀននឹងនៅផ្ទះរបស់ឈ្មោ[redacted] លីកវៃ ទៀត ។ ដូច្នេះវត្ថុដែលដកហូតនេះគឺដកហូតតែពីជនជាប់ចោទឈ្មោ[redacted] លីកវៃ គឺមិនមានពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] សុខឡា ទេ ។ ចំណុចនេះសំខាន់ណាស់ដែលតុលាការកំពូលចង្អុលបង្ហាញឱ្យវែកញែក ហើយចំពោះគ្រឿងញៀន ១ខាំ នេះដែលនាំឱ្យតុលាការកំពូលចង្អុលបង្ហាញផ្តែកទៅលើការសង្ស័យដោយឱ្យសាលាឧទ្ធរណ៍ពិចារណាឡើងវិញនឹង ថ្នាំញៀន១ខាំ នេះត្រូវបានលោ[redacted] ច័ន្ទតារា គាត់បានធ្វើជាលាយលក្ខណ៍អក្សរ ក៏បានឆ្លើយបញ្ជាក់នៅសវនាការពេលនេះថា ថ្នាំញៀន ១ខាំ នឹងមិនមែនជារបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡា នោះទេ គ្រាន់តែជាការញុះញ៉ង់ ហើយការពិតវិន្និច្ឆ័យគឺបានឃើញនៅផ្ទះរបស់ជនជាប់ចោទឈ្មោះ [redacted] លីកវៃ ។ ពីរចំណុចនេះធន់ល្មមដែលអាចឱ្យក្រុមប្រឹក្សាអាចពិនិត្យពិចារណាបាន អំពីភាពស្អាតស្អំ និងអំពីគ្មានពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡា បានឈានទាមទារដោយសារជនជាប់ចោទឈ្មោះ [redacted] សុខឡា មិនបានប្រព្រឹត្ត ហើយប្រសិនបើផ្តន្ទាទោសគាត់ ២៥ឆ្នាំ ដោយគ្មានកំហុសគឺមានភាពអយុត្តិធម៌ ។ ហេតុនេះយោងតាមមាត្រា ៣៥០ និងមាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] សុខឡា គ្មានពិរុទ្ធភាពទេ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យជនជាប់ចោទឈ្មោះ [redacted] សុខឡា រួចផុតពីបទចោទប្រកាន់ និងដោះលែងឱ្យជនជាប់ចោទមានសេរីភាពវិញ ។

-លោ[redacted] សុភា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីកវៃ និងជនជាប់ចោទឈ្មោ[redacted] មួយនី បានធ្វើសេចក្តីសន្និដ្ឋានថា ៖ នៅក្នុងចំណុចទី៣ របស់តុលាការកំពូលបានចង្អុលបង្ហាញថា ការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លីកវៃ ២៥ឆ្នាំ នេះ ដោយថ្នាំញៀនមានច្រើនជិត ២គីឡូ ហើយតុលាការកំពូលយល់ថាចាប់ពី ២៤០ក្រាមទៅ គឺចាប់ពី ២០ (ម្ភៃ)ឆ្នាំ ឡើង ។ ចំណុចនេះសូមធ្វើការកត់សម្គាល់ដែរថា អតិប្បបរមានៃទោសបទគ្រឿងញៀងគឺ ៣០ឆ្នាំ ហើយបទល្មើសគ្រឿងញៀនខ្លះគឺមានដល់រាប់តោន អញ្ចឹងអតិប្បរមានៃទោសនឹងគឺយើងមិនអាចកំណត់តាមចំនួនក្រាមនៃគ្រឿងញៀននឹងទេ យល់ឃើញថា បើសិនជាយើងកំណត់ថា គ្រឿងញៀនប៉ុន្មានតោនបាន ៣០ឆ្នាំ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] លីកវៃ និងគ្រឿងញៀនគាត់មិនដល់ ៤គីឡូ ឬ៥គីឡូ ឬមិន



Scanned with CamScanner

ដល់ ២គីឡូ ផង នេះជាចំណុចមួយ មួយវិញទៀតគាត់មិនបានយល់ដឹងថារឿងគ្រឿងញៀនពិតប្រាកដវាមានគីឡូរអញ្ចឹងវាមានទោសធ្ងន់អញ្ចឹងទេ ខ្លួនយល់ថាគាត់មិនបានដឹងប្រសិនបើគាត់ដឹងគាត់មិនប្រថុយយកកូនទៅផង ហើយបានលុយតែ២៥ដុល្លារនឹង ទៅប្រថុយទៅនឹងការជាប់គុក ២០ឆ្នាំទៅ ៣០ ឆ្នាំ នឹង យល់ថាគាត់មិនបានដឹងទេបានជាគាត់យកទៅនឹងធ្វើជាសេវាព្រោះគាត់ជាអ្នកដឹកភ្ញៀវ ។ ការដែលសាលាឧទ្ធរណ៍បាត់ដំបងផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted]បឹកផៃ ២៥ឆ្នាំ នឹង គឺមានភាពសមរម្យហើយព្រោះថាជនជាប់ចោទឈ្មោះ [redacted]លឹកផៃ គាត់មិនធ្លាប់មានប្រវត្តិនៃការផ្តន្ទាទោសពីមុនមកទេ លើកទីមួយរបស់គាត់ ដោយសារតែគាត់ខ្វះការយល់ដឹង ហើយពេលសមត្ថកិច្ចចាប់ខ្លួននឹងគាត់មិនមានការប្រឆាំងតបតអ្វីនោះទេ គាត់បានសហការ ហើយជាពិសេសគាត់មិនមែនជាម្ចាស់ថ្នាំញៀននោះទេគាត់ខ្លួនតែជាមនុស្សដែលគេប្រើឱ្យដឹកតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតគាត់បានលើកឡើងតាំងពីសវនាការលើកមុនគាត់សូមជួយបន្ធូរបន្ថយទោសដល់គាត់ខ្លះ គាត់សង្ឃឹមថានៅពេលដែលគាត់ចេញពីពន្ធនាគារវិញគាត់បានជួបកូនគាត់ចំនួន ៤នាក់ ។ ដូច្នេះ យល់ឃើញថា ទោស ២៥ឆ្នាំ និងគឺសមរមហើយ ចំពោះទោសពិន័យជាប្រាក់គឺគាត់មានជីវភាពក្រីក្រមិនមានលទ្ធភាពបង់ប្រាក់ពិន័យទេ ។ មួយទៀតពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted]មួយនី តុលាការកំពូលគិតថាមិនទាន់បានធ្វើការអង្កេត និងស្រាវជ្រាវឱ្យបានល្អិតល្អន់ដើម្បីស្វែងរកភស្តុតាងនិងភាពស៊ីសង្វាក់ផ្សេងណាមួយមកដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] មួយនី ទេ យល់ឃើញថា មិនមែនមិនបានធ្វើការអង្កេតនោះទេ មុននឹងឈានមកដល់សវនាការឆ្លងកាត់នីតិវិធីស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌របស់តំណាងអយ្យការ របស់ចៅក្រមស៊ើបសួរ ។ ដោយផ្អែកតាមច្បាប់គាត់គឺជាជនជាប់ចោទនៅពេលដែលសវនាការ ហើយតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានបញ្ជាក់ថា រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ហើយឆ្លងកាត់នីតិវិធីស៊ើបអង្កេត នីតិវិធីស៊ើបសួរ និងជំនុំជម្រះកន្លងមកគឺមានតែរបាយការណ៍សំយោគរបស់សមត្ថកិច្ចមួយទេដែលបញ្ជាក់ថា [redacted] មួយនី នឹងគាត់បានវេរលុយពាក់ព័ន្ធនឹងការជួញដូរគ្រឿងញៀន ប៉ុន្តែយើងមិនមានភស្តុតាងបញ្ជាក់ច្បាស់ថាវេរទៅណាទៅណាចំនួនប៉ុន្មាននោះទេ គ្រាន់តែថាឃើញលេខកុងវេរទៅទាក់ទងនឹងវេរលុយតែប៉ុណ្ណោះ នេះគ្រាន់តែជាការសង្ស័យ ប៉ុន្តែឆ្លងតាមការស៊ើបអង្កេត ស៊ើបសួរមិនមានភស្តុតាងដាក់បន្ទុកអ្វីផ្សេងនោះទេ ។ ម្យ៉ាងទៀតសមត្ថកិច្ចមិនបានឃាត់ខ្លួនគាត់នោះទេ ហើយពេលដែលឈ្មោះ[redacted] លឹកផៃ និងគេឃាត់ខ្លួនតាំងពីថ្ងៃទី០៨ ហើយរបាយការណ៍សំយោគគឺបញ្ចប់បញ្ជូនមកតុលាការថ្ងៃទី១១ និយាយទៅគឺ ៣ ថ្ងៃ គឺឈ្មោះ [redacted] មួយនី គាត់យកបាយទឹកទៅឱ្យឈ្មោះ[redacted] លឹកផៃ ទាំងព្រឹក និងល្ងាច ហើយមិនមានរបាយការណ៍ ឬក៏កំណត់ហេតុអ្វីគឺមិនមានកំណត់ហេតុណាមួយសួរឈ្មោះ[redacted] មួយនី ទេ មិនឃើញមានកំណត់ហេតុសាកសួរសោះនៅមន្ត្រីនគរបាល ស្រាប់តែរបាយការណ៍សំយោគដាក់ឈ្មោះ[redacted] មួយនី ដែរ ហើយដាក់គេចខ្លួន ហើយគាត់មកកន្លែងរហូតគាត់មកកន្លែងប៉េអឹមរហូត

នេះគ្រាន់តែជាការសង្ស័យមួយរបស់សមត្ថកិច្ច ប៉ុន្តែនៅពេលដែលឆ្លងកាត់នីតិវិធីអស់ហើយគឺមិនមានភស្តុតាងអ្វីដាក់បន្ទុកទៅលើឈ្មោះ [redacted] មួយនី សោះ មានតែរបាយការណ៍សំយោគមិនមានចម្លើយរបស់ឈ្មោះ [redacted] មួយនី ផង ។ ហើយនៅក្នុងសំអាងហេតុរបស់សាលាឧទ្ធរណ៍ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យឃើញថា មិនមានមូលដ្ឋានណាមួយដែលអាចធ្វើជាភស្តុតាងបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] មួយនី បានប្រើលេខទូរស័ព្ទណាមួយ នឹងមានការវេរលុយពីអ្នកណាដែលមានផ្ទុះបញ្ចាំងទៅនឹងរបាយការណ៍សរុបដែលបានបង្ហាញតែទៅលើការវេរលុយពីឈ្មោះ [redacted] សុខឡា ទៅឈ្មោះ [redacted]ហៅ ស្រីពៅ រហ័សនាម"កន្សែងក្រហម" កាន់លេខទូរស័ព្ទ ០៦៩ ៨៥ ៤០ ៤២ លេខទំនាក់ទំនងលក់គ្រឿងញៀន ហើយជាអ្នកបញ្ជាមកឈ្មោះ [redacted] លីកផៃ យកថ្នាំញៀនទៅឱ្យនៅចំណុចរង្វង់មូលផ្លូវ ៦០ម៉ែត្រ ហើយមិនមានវត្តមាននៃការវេរប្រាក់ពីឈ្មោះ [redacted] សុខឡា និងឈ្មោះ [redacted] ហៅ ស្រីពៅ រហ័សនាម "កន្សែងក្រហម" ទៅឈ្មោះ [redacted] មួយនី នោះទេ ។ ដែលចំណុចនេះក្រុមប្រឹក្សាជំនុំជម្រះយល់ថា នៅមានភាពមន្ទិលសង្ស័យនៅឡើយដែលគ្រាន់តែជាការសង្ស័យប៉ុណ្ណោះ ដែលនាំឱ្យមានជាវិមតិសង្ស័យដែលជាប្រយោជន៍ដល់ជនជាប់ចោទ ។ ដូច្នេះ ការយល់ឃើញរបស់សាលាឧទ្ធរណ៍បាត់ដំបងនេះគឺមានលក្ខណៈគ្រប់គ្រាន់ហើយ ប៉ុន្តែតុលាការកំពូលបែរជាយកឃ្លាដែលសន្និដ្ឋានរបស់មេធាវីយកមកចង្អុលទៅវិញ ។ ម្យ៉ាងទៀតឈ្មោះ [redacted] មួយនី ដោយសារតែនៅសាលក្រមសាលាដំបូងខេត្តសៀមរាបមានចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ដូច្នេះហើយគាត់មិនហ៊ាននៅផ្ទះទេ កូនគាត់៤នាក់ត្រូវរៀនសូត្រ ហើយត្រូវយកទៅផ្ញើបងប្អូនពាសវាលពាសកាលគាត់រត់គេចខ្លួនមិនមានអ្នកណាមើលកូនវាជារឿងមួយដែលគួរឱ្យអាណិតខ្លោចផ្សារចំពោះគាត់ ។ ដូច្នេះ សំណូមពររក្សាសេចក្តីសម្រេចនៅក្នុងសាលដីកាលេខ ៣៦ (ង) ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ទុកជាបានការដដែល ។

-លោក [redacted] ម៉េង មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីកផៃ និងជនជាប់ចោទឈ្មោះ [redacted] មួយនី បានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនសូមស្របតាមសេចក្តីសន្និដ្ឋានការពាររបស់លោក [redacted] សុភា មេធាវីការពារសិទ្ធិឱ្យជនបជាប់ចោទឈ្មោះ [redacted] លីកផៃ និងជនជាប់ចោទឈ្មោះ [redacted] មួយនី ។ ខ្លួនគ្រាន់តែចង់បញ្ជាក់បន្ថែមថា របាយការណ៍ទាំងសាលាដំបូងខេត្តសៀមរាប ទាំងតុលាការកំពូលបានចាប់អារម្មណ៍ទៅលើរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌លេខ ០៩២/២០២០ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ របស់ការិយាល័យបទល្មើសគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តសៀមរាប នៅពេលនេះអ្នកដែលធ្វើរបាយការណ៍គឺសាក្សីឈ្មោះ [redacted] ច័ន្ទតារា នេះគាត់បានបញ្ជាក់ហើយថា ភស្តុតាងដាក់បន្ទុកទៅលើឈ្មោះ [redacted] មួយនី មិនមានទេ គ្រាន់តែឃើញទូរស័ព្ទគាត់មានវេរលុយចេញចូលតែប៉ុណ្ណោះ អញ្ចឹង តុលាការកំពូលបានចង្អុលបង្ហាញដែរថាការស៊ើបអង្កេតអំពីឈ្មោះ [redacted] មួយនី នេះមិនបានធ្វើឡើងច្បាស់លាស់គ្រប់ជ្រុងជ្រោយនោះទេ ហើយបានបញ្ជាក់ឱ្យឃើញច្បាស់ហើយថាឈ្មោះ [redacted] មួយនី មិនជាប់ពាក់ព័ន្ធនឹងបទល្មើសជួញដូរដោយខុស



Scanned with CamScanner

ច្បាប់នូវសារធាតុញៀន ប្រព្រឹត្តកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ នោះទេ ។ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់ ៣៦(ង) ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿងព្រហ្មទណ្ឌ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង
## យល់ឃើញថា

១-សំណុំរឿងព្រហ្មទណ្ឌលេខ ១៩ ត.៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រូវបានតុលាការកំពូលបង្វិលមកសាលាឧទ្ធរណ៍វិញ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ២៧៦ "III" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់តុលាការកំពូល ដូចនេះសាលាឧទ្ធរណ៍បាត់ដំបង មានសមត្ថកិច្ចទទួលយកសំណុំរឿងនេះមកជំនុំជម្រះបានតាមច្បាប់ យោងតាមបញ្ញត្តិមាត្រា ៤៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-សាលដីកាព្រហ្មទណ្ឌលេខ ៣៦(ង) ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍បាត់ដំបង ត្រូវបានតុលាការកំពូលបដិសេធចោលត្រង់ចំណុចទី៣, ៣.១ , ៣.២ និងចំណុចទី៤ នៃសេចក្តីសម្រេច ។ ដូចនេះសាលាឧទ្ធរណ៍មិនលើកយកសាលដីកា និងសាលក្រមខាងលើមកធ្វើការពិចារណាទៀតទេ ។

៣-នាពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ [redacted] សុខឡា បានឆ្លើយថា ខ្លួនមិនបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀនឡើយ ហើយប្រាក់ចំនួន ១០០,០០០៛ (ដប់ម៉ឺន)រៀល នោះខ្លួនខ្ចីពីមិត្តភក្តិឈ្មោះ ស្មី សំណូមពរជួយសម្រាលទោសឱ្យខ្លួនផង ។ ការអះអាង និងសំណូមពរនេះមិនអាចឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍លើកយកមកពិចារណាឡើយ ព្រោះថានៅពេលឃាត់ខ្លួនជនជាប់ចោទរូបនេះ គឺមានប្រាក់ចំនួន ៦០,០០០៛ (ប្រាំមួយម៉ឺន)រៀល នៅនឹងខ្លួនដែលជាប្រាក់សម្រាប់ញុះញង់ក្នុងការទិញគ្រឿងញៀន ដែលសមត្ថកិច្ចបានថតលេខលុយទុករួចជាស្រេច ហើយបើតាមអង្គហេតុនៃការចោទប្រកាន់ ក៏ដូចជាភស្តុតាងដែលប្រមូលបានគឺកំណត់ថា ជនជាប់ចោទរូបនេះពិតជាបានទំនាក់ទំនងក្នុងការទិញគ្រឿងញៀនឱ្យភ្នាក់ងារ K7 ក្នុងទម្ងន់ ១០០ (មួយរយ) ក្រាម ដែលនៅពេលទទួលបានប្រាក់ចំនួន ៣,៣០០,០០០៛(បីលានបីសែន)រៀល រួចហើយ ជនជាប់ចោទក៏បានជិះម៉ូតូចេញ



Scanned with CamScanner

ទៅ ហើយក្នុងរយៈពេល ២០នាទី ក្រោយមកក៏មានគេទំនាក់ទំនងមក K7 ថាតិចទៀតមានគេទាក់ទង យកគ្រឿងញៀនមកឱ្យអ្នកដែលទាក់ទងជាសំឡេងស្រីមានឈ្មោះថា យ៉ា ហៅ ស្រីពៅ ហៅកន្សែង ក្រហម កាន់លេខទូរស័ព្ទ ០៦៩ ៨៥ ៤០ ៤២ ។ បន្តិចក្រោយមកក៏មានគេតេមក K7 ឱ្យទៅយកថ្នាំ ញៀននៅរង្វង់ផ្លូវកែវ ៦០ម៉ែត្រ បានប្រគល់របស់០១ដុំ ពេលនោះសមត្ថកិច្ចទៅដល់ក៏បានឃាត់ខ្លួនជន ជាប់ចោទឈ្មោះ [redacted] លីកផៃ និងបានដកហូតថ្នាំញៀនចំនួន ១០០ g (មួយរយ)ក្រាម ហើយបន្តទៅ ឆែកឆេរនៅផ្ទះរបស់ឈ្មោះ [redacted] លីកផៃ បានរកឃើញថ្នាំញៀនមួយចំនួនធំថែមទៀត និងក្រោយមក ឃាត់ខ្លួនឈ្មោះ [redacted] សុខឡា នេះ និងមានក្រដាសប្រាក់ញ៉ុះញង់សល់ ៦.០០០០ (ប្រាំមួយម៉ឺន)រៀល ។ ដូច្នេះតាមអង្គហេតុនេះបញ្ជាក់ច្បាស់ហើយថាឈ្មោះ [redacted] សុខឡា ជាអ្នកទំនាក់ទំនងទិញថ្នាំញៀនពី ឈ្មោះ យ៉ា ហៅ ស្រីពៅ ដែលបានទទួលកម្រៃសេវាចំនួន ១០០.០០០៛ (ដប់ម៉ឺន)រៀល ដោយមានភស្តុ តាងតាមរយៈជនជាប់ចោទឈ្មោះ [redacted] សុខឡា បានទាក់ទងទៅលេខទូរស័ព្ទរបស់ខ្លួនដែលខ្លួនទទួល ស្គាល់ទៅលេខ ០៦៩ ៨៥ ៤០ ៤២ ហើយឈ្មោះ យ៉ា ហៅ ស្រីពៅ បានទាក់ទងមកឈ្មោះ [redacted] លីកផៃ ឱ្យយកថ្នាំញៀនចំនួន ១០០g (មួយរយ)ក្រាម មកឱ្យ K7 នៅកន្លែងណាត់ជួប ។ ចំពោះឈ្មោះ [redacted] សុខ ឡា បានឆ្លើយថាឈ្មោះ ស្មី បានឱ្យប្រាក់ខ្លួនចំនួន ១០.០០០០ (ដប់ម៉ឺន)រៀល ខ្លីចាយនោះ ជាការឆ្លើយ មិនមានហេតុផល និងមានចម្លើយឈ្មោះ ស្មី មកឆ្លើយបញ្ជាក់ឡើយ ។

៤-នាពេលសវនាការនេះជនជាប់ចោទឈ្មោះ [redacted] លីកផៃ បានឆ្លើយសារភាពថា ខ្លួនពិតជាបាន ប្រព្រឹត្តដូចការចោទប្រកាន់មែន នៅថ្ងៃកើតហេតុខ្លួនពិតជាបានយកថ្នាំញៀនចំនួន ១០០ g (មួយរយ) ក្រាម លក់ឱ្យ K7 ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ហើយក្រោយមកបន្តទៅឆែកឆេរនៅផ្ទះរបស់ខ្លួនបានគ្រឿង ញៀនចំនួន ១៨៥៤,៤ក្រាម ។ សូមឱ្យសាលាឧទ្ធរណ៍សម្រេចបន្ធូរបន្ថយទោសដល់ខ្លួនផង ខ្លួនដឹង កំហុសហើយ ។

៥-តុលាការកំពូលបានចង្អុលបង្ហាញត្រង់សំអាងហេតុចំណុច ២ ដោយដកស្រង់ដោយសង្ខេបថា "ផ្អែកលើចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខឡា និងចម្លើយ K7 ដោយបញ្ជាក់ថា សារធាតុ ញៀនដែលកម្លាំងសម្ងាត់ K7 ញុះញង់ឱ្យឈ្មោះ [redacted] សុខឡា ជួញដូរនោះមានទម្ងន់ត្រឹមតែចំនួន ១០០ ក្រាម ប៉ុណ្ណោះ" ។ ប៉ុន្តែសារធាតុញៀននេះតាមប្រភពដើមគឺជារបស់ជនជាប់ចោទឈ្មោះ [redacted] លីកផៃ ដូច្នេះកម្រិតភាពសុទ្ធនៃសារធាតុញៀននេះដូចគ្នានឹងសារធាតុញៀនដែលដកហូតបានពីឈ្មោះ [redacted] លីក ផៃ ហើយបានដកសំណាកយកទៅធ្វើកោសលវិច័យដែលជាលទ្ធផលគឺជាមេតំហ្វេតាមីនដែលមាន កម្រិតភាពសុទ្ធ ៧៦,០៦% ដូច្នេះធាតុសុទ្ធមេតំហ្វេតាមីនសរុបចំនួន ១០០ក្រាម ស្មើនឹងចំនួន ៧៦,០៩g (ជិតសិបប្រាំមួយក្បៀសសូន្យប្រាំមួយ)ក្រាម វាស្ថិតនៅចន្លោះកម្រិតកំណត់ចាប់ពី ៥ក្រាមរហូតដល់ ៨០ក្រាម ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួត ពិនិត្យគ្រឿងញៀន ។ ដូច្នេះឃើញថា ផ្អែកតាមការចង្អុលបង្ហាញនេះពិតជាមានភស្តុតាង និងអំណះ អំណាងដូចដែលតុលាការកំពូលបានចង្អុលបង្ហាញមែន ដែលគប្បីសាលាឧទ្ធរណ៍លើកយកមក



Scanned with CamScanner

ពិចារណា និងសម្រេចបាន ដើម្បីកំណត់អំពីកម្រិតទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] សុខឡា ហៅ ក្តួ ឡើងវិញ ។

៦-ការឆ្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ច័ន្ទតារា និងឈ្មោះ [redacted] ណាក់ គឺមានភាពផ្ទុយពីរបាយការណ៍សំយោគរបស់ខ្លួនដែលជាមន្ត្រីធ្វើរបាយការណ៍តាមលេខ ០៩២/២០២០ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០ របស់ការិយាល័យគ្រឿងញៀននៃកងរាជអាវុធហត្ថខេត្តសៀមរាបបានបញ្ជាក់ថា ឈ្មោះ [redacted] សុខឡា ហៅ អាក្តួ ជាអ្នកទទួលប្រាក់ ហើយវេរប្រាក់ទៅឱ្យឈ្មោះ យ៉ា ហៅ ស្រីពៅ តាមលេខទូរស័ព្ទ ០៦៩ ៨៥ ៤០ ៤២ លេខសម្រាប់ទាក់ទងទិញគ្រឿងញៀន និងវេរប្រាក់ចូល ហើយឈ្មោះ យ៉ា ហៅ ស្រីពៅ ជាអ្នកបញ្ជាមកឈ្មោះ [redacted] លីកឆៃ យកថ្នាំញៀនទៅឱ្យគេនៅរង្វង់មូលផ្លូវ ៦០ម៉ែត្រ ដែលឈ្មោះ [redacted] សុខឡា ជាខ្លួនពិតជាមានការទំនាក់ទំនងគ្នាតាមទូរស័ព្ទ និងឈ្មោះ យ៉ា ហៅ ស្រីពៅ មែនតែជាការសួរសុខទុក្ខគ្នាប៉ុណ្ណោះ ។

៧-តុលាការកំពូលបានចង្អុលបង្ហាញក្នុងសំអាងហេតុចំណុច៣ លើជនជាប់ចោទឈ្មោះ [redacted] លីកឆៃ ថា "ការដែលសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបងបានសម្រេចកែប្រែការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] លីកឆៃ ពីដាក់ពន្ធនាគារកំណត់រយៈ ៣០ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០០ (មួយរយលាន) រៀល មកជាដាក់ពន្ធនាគាររយៈពេល ២៥ឆ្នាំ ដោយពុំមានការផ្ដន្ទាទោសពិន័យជាប្រាក់នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា ក្នុងការពិចារណាដើម្បីសម្រេចអំពីកម្រិតទោសក្នុងការអនុវត្តច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដោយផ្អែកលើកម្រិតធាតុសុទ្ធនៃសារធាតុញៀន ដែលបានចាប់យកធៀបទៅនឹងកម្រិតធាតុសុទ្ធនៃសារធាតុញៀនមានចែងក្នុងមាត្រា ៤០ កថាខណ្ឌ៧ ចំណុចទី៤ មេតំហ្វេតាមីនមានបរិមាណសុទ្ធចាប់ពី ២៤០ក្រាម ឡើងទៅ ។ ឯសារធាតុញៀនដែលបានចាប់យកក្នុងរឿងក្ដីនេះមានបរិមាណសរុប ១៨៥៤,៤ក្រាម និងមានសារធាតុញៀនសុទ្ធប្រភេទមេតំហ្វេតាមីនរហូតដល់ ៧៦,០៦% ឯនោះ ។ ចំណែកឯការមិនសម្រេចប្រកាសទោសពិន័យជាប្រាក់គឺជាការអនុវត្តមិនបានត្រឹមត្រូវតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងបញ្ញត្តិមាត្រា ៦៦៨ ត្រង់កថាខណ្ឌទី១ និងទី៣ នៃក្រមព្រហ្មទណ្ឌឡើយ ដែលចំណុចនេះត្រូវបានអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាដំបូងខេត្តបាត់ដំបងប្ដឹងសាទុក្ខជាប្រយោជន៍ច្បាប់" ។ ត្រង់ចំណុចនេះសាលាឧទ្ធរណ៍យល់ស្របតាមសំអាងហេតុរបស់តុលាការកំពូលខាងលើទាំងស្រុង គប្បីសម្រេចលើទោសពិន័យនេះ ។

៨-តុលាការកំពូលបានចង្អុលបង្ហាញត្រង់ចំណុច៣ លើជនជាប់ចោទឈ្មោះ [redacted] មួយនី ដោយលើកឡើងថា "តុលាការកំពូលពិនិត្យឃើញថា សំអាងហេតុរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង ត្រង់ចំណុចនេះ ពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា ពុំមានធាតុផ្សំនៃបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនចំពោះជនជាប់ចោទឈ្មោះ [redacted] មួយនី នោះទេ" ។ ដែលគប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ពិនិត្យពិចារណា និងលើកយកសំអាងហេតុឱ្យបានគ្រប់ជ្រុងជ្រោយស្របតាមសេចក្ដីសម្រេចរបស់ខ្លួន ព្រោះតាមភស្តុតាងជាសារធាតុញៀនដែលសមត្ថ



Scanned with CamScanner

កិច្ចធ្វើការបង្ក្រាប និងរកឃើញបានគីស្កើតក្នុងលំនៅឋានរបស់ជនជាប់ចោទឈ្មោះ [redacted] បើកវៃ និងឈ្មោះ [redacted] មួយនី ដែលជាប្ដីប្រពន្ធនឹងគ្នារស់ក្នុងផ្ទះនោះជាមួយគ្នា ហើយមានការវេរប្រាក់តាមលេខទូរស័ព្ទផង ។ ត្រង់ចំណុចនេះឆ្លងតាមសវនាការនេះ សាលាឧទ្ធរណ៍បាត់ដំបងពិចារណាឃើញថា ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោ [redacted] បើកវៃ និងសាក្សី ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] មួយនី ដូចការចោទប្រកាន់ឡើយ ដូចតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បើកវៃ បានឆ្លើយថា ប្រពន្ធរបស់ខ្លួនមិនបានដឹង និងជាប់ពាក់ព័ន្ធនឹងគ្រឿងញៀនទេ ហើយគ្រឿងញៀននេះជារបស់ខ្លួនពិតមែន ហើយនៅពេលសមត្ថកិច្ចបង្ក្រាបនឹងឆែកឆេររកឃើញថ្នាំញៀនគឺនៅបន្ទប់ជាន់លើ ដែលវេចខ្ចប់ក្នុងថង់ខ្មៅរុំក្រដាសកាសែត និងដាក់ក្នុងធុងយ៉ាងបិទជិត ហើយជាបន្ទប់ទំនេរដោយខ្លួននិងប្រពន្ធគេងនៅជាន់ក្រោម ដូច្នេះត្រង់នេះបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] មួយនី មិនបានដឹងឡើយ ។ ចំណុចដែលថា នៅក្នុងលេខទូរស័ព្ទមានទទួលការវេរប្រាក់ចូលដែលបានមកពីលក់គ្រឿងញៀននោះគឺមិនមានភស្តុតាងច្បាស់លាស់មកបញ្ជាក់ថាជាការវេរប្រាក់ក្នុងការទិញលក់គ្រឿងញៀន ហើយវេរពីអ្នកណាមកលេខទូរស័ព្ទអ្នកណា និងវេរពីទីកន្លែងណាមកឡើយ ។ ម្យ៉ាងទៀតសាក្សីឈ្មោះ [redacted] ច័ន្ទតារា និងឈ្មោ [redacted] ណាក់ ក៏បានឆ្លើយបញ្ជាក់នាពេលសវនាការនេះថា ជនជាប់ចោទនេះមិនមែនជាមុខសញ្ញាធ្លាប់ជួញដូរគ្រឿងញៀន និងគ្មានភស្តុតាងដាក់បន្ទុកទេ ។

៩-ផ្អែកតាមចម្លើយសាក្សី ចម្លើយជនជាប់ចោទឈ្មោះ [redacted] បើកវៃ និងភស្តុតាងដែលបានពិនិត្យក្នុងសវនាការនេះ ក៏ដូចជាសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី គឺមានភស្តុតាងដែលបញ្ជាក់ថា ជនជាប់ចោទគ្មានកំហុសឡើយ ។ ត្រង់ចំណុចនេះបញ្ជាក់ឱ្យឃើញថា គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទនោះទេ ដោយផ្អែកតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានខ្លឹមសារជាគោលការណ៍ថា តុលាការសំអាងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ហើយមាត្រា ៣៥៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ។ ដូច្នេះផ្អែកតាមមាត្រា ៣៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា វិមតិសង្ស័យត្រូវតែបានជាប្រយោជន៍ដល់ជនជាប់ចោទជានិច្ច ។

១០-តំណាងមហាអយ្យការបានសន្និដ្ឋានថា សូមឱ្យក្រុមប្រឹក្សាសាលាឧទ្ធរណ៍ពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។ សេចក្ដីសន្និដ្ឋាននេះក្រុមប្រឹក្សាពិចារណា និងសម្រេចបានដូចមានក្នុងសំអាងហេតុខាងលើ ។

១១-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខឡា បានសន្និដ្ឋានថា ផ្អែកតាមសវនាការនេះ គឺគ្មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឡើយ ស្នើសុំឱ្យក្រុមប្រឹក្សាសម្រេចឱ្យកូនក្ដីខ្លួនរួចផុតពីបទចោទ និងដោះលែងជនជាប់ចោទឱ្យមានសេរីភាពវិញ ។ សេចក្ដីសន្និដ្ឋាន



Scanned with CamScanner

ការពារសុំឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់គឺគ្មានទឡ្ហីករណ៍ និងភស្តុតាងសមស្របដែលអាចឱ្យសភាព្រហ្មទណ្ឌលើកយកមកពិចារណា និងសម្រេចបានឡើយ ។

១២-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]លីកផៃ បានសន្និដ្ឋានជារួមថា កូនក្តីខ្លួនបានសារភាព និងទទួលស្គាល់កំហុសរួចហើយ ស្នើសុំឱ្យក្រុមប្រឹក្សាសម្រេចដូចការសម្រេចរបស់សាលាឧទ្ធរណ៍ដដែល ។ សេចក្តីសន្និដ្ឋានការពារត្រង់ចំណុចនេះមិនសមស្របតាមគតិច្បាប់ឡើយ ការដែលត្រឹមត្រូវដូចការចង្អុលបង្ហាញរបស់តុលាការកំពូល ដែលសាលាឧទ្ធរណ៍បានលើកយកមកពិចារណាមកសំអាងហេតុខាងលើ ។

១៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] មួយនី បានសេចក្តីសន្និដ្ឋានជារួមថា គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងនៅតែមានវិមតិសង្ស័យដែលបញ្ជាក់ថា កូនក្តីខ្លួនមិនបានប្រព្រឹត្តខុសឡើយ ព្រោះគ្មានអង្គហេតុដែលថា កូនក្តីខ្លួនបានធ្វើសកម្មភាពលក់ដូរគ្រឿងញៀន និងទទួលប្រាក់ក្នុងការទិញលក់គ្រឿងញៀន សូមសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ។ សេចក្តីសន្និដ្ឋាននេះមានទឡ្ហីករណ៍ត្រឹមត្រូវដូចក្នុងសំអាងហេតុ និងសំអាងច្បាប់ខាងលើ ។

១៤-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] សុខឡា ហៅ ភ្លូ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៥-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted] លីកផៃ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំ សង្កាត់ស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៦-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ[redacted]មួយនី ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ គប្បីសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីការចោទប្រកាន់ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩ ត.៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង តាមអំណាចសាលដីកាសភាព្រហ្មទណ្ឌលេខ ២៧៦ "III" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ របស់តុលាការកំពូល ។



Scanned with CamScanner

២-ផ្តន្ទាទោសៈ

ក.ឈ្មោះ [redacted] សុខឡា ហៅ ភួ ភេទប្រុស កើតថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩១ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល ។

ខ.ឈ្មោះ [redacted] លីកវៃ ភេទប្រុស អាយុ៤៤ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់ ២៥ (ម្ភៃប្រាំ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល ។

គ.ឱ្យជនជាប់ចោទឈ្មោះ [redacted] មួយនី ភេទស្រី អាយុ៣៥ឆ្នាំ ដែលមានសាវតាជាតិដូចខាងលើ រួចផុតពីបទចោទប្រកាន់ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទ្រាំង សង្កាត់ស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃ០៨ ខែមេសា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៧ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] សុខឡា ហៅ ភួ និងឈ្មោះ [redacted] លីកវៃ ។

៤- បង្គាប់ឱ្យបញ្ឈប់ចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] មួយនី ដែលមានសាវតាជាតិដូចខាងលើ ។

៥-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខឡា និងឈ្មោះ [redacted] លីកវៃ ដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] មួយនី ។

រក្សាសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍បាត់ដំបង, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner